# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីសេរីភាពតាមផ្លូវលោកនិងសេរីភាពតាមផ្លូវធម៌

Website: www.hoksavann.org

ថ្ងៃទី២១ វិច្ឆិកា ២០០៤

### ១- អំពីសេរីភាពតាមផ្លូវលោក ៖

ពាក្យថាសេរីភាពដែលភាសាបារាំងថា Liberté អង់គ្លេសថា Liberty ឬ Freedom តាមផ្លូវលោកដែលគេឲ្យន័យហើយថា គឺជាសិទ្ធិឬអំណាចរបស់បុគ្គលម្នាក់ៗ ដែលគេអាចធ្វើអ្វីបាន នៅក្រោមអំណាចច្បាប់សង្គម ។ សង្គមមនុស្សជាសង្គមមានបញ្ញាជាងសង្គមសត្វតិរច្ឆាន ចេះរៀបចំសង្គមរបស់ខ្លួន ឲ្យបានលូតលាស់ចំរើននិងប្រកបដោយសីលធម៌ថ្លៃថ្នូរ ដូចជាការចេះគោរពសិទ្ធិគ្នាទៅវិញទៅមកជាដើម ។ សេរីភាពរបស់បុគ្គលមួយរូបៗដែលអង្គការសហប្រជាជាតិនិងប្រទេសកាន់របបប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្សបានចែងក្នុងច្បាប់ថា បុគ្គលគ្រប់រូបមានសេរីភាពខាងការនិយាយ បញ្ចេញមតិ មានសេរីភាពខាងការសិក្សា មានសេរីភាពខាងការប្រកបអាជីវកម្មផ្សេងៗ មានសេរីភាពខាងការតាំងទីលំនៅ មានសេរីភាពខាងការធ្វើនយោបាយ មានសេរីភាពខាងការសរសេរសារពត៌មាន មានសេរីភាពខាងការធ្វើបាតុកម្មជាដើម ។ ច្បាប់សេរីភាពនេះបានចែងជាគោលការណ៍ថា ជនគ្រប់រូបអាចធ្វើអ្វីបានទាំងអស់ កុំឲ្យតែប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ។

### ២- អំពើសេរីភាពខាងផ្លូវធម៌ ៖

សេរីភាពខាងផ្លូវធម៌នៃព្រះពុទ្ធសាសនា គឺការរំដោះខ្លួនចេញពីកិលេសតណ្ហា ព្រោះកិលេសតណ្ហានេះរុំព័ទ្ធចិត្តគំនិតរបស់មនុស្ស មិនឲ្យចិត្តគំនិតមានសិទ្ធិសេរីភាព ។ មនុស្សសត្វជាខ្ញុំនៃតណ្ហា តណ្ហាដឹកនាំមនុស្សសត្វឲ្យធ្វើល្អខ្លះអាក្រក់ខ្លះ ។ តណ្ហាមានកង្វះខាតជានិច្ចមិនចេះគ្រប់គ្រាន់ឡើយ ប្រៀបដូចទឹកសមុទ្រមិនចេះពេញប្រៀបដោយទឹកឡើយ ។ បុគ្គលខ្លះក្នុងលោកនេះ ដោយសារកិលេសតណ្ហារបស់ខ្លួនខ្លាំងបានប្រព្រឹត្តធ្វើអំពើដ៏អាក្រក់ទៅលើជនដទៃ ដើម្បីបំពេញតណ្ហារបស់ខ្លួន ។ បើបុគ្គលមិនលុះក្នុងអំណាចតណ្ហាដឹកនាំ មានបញ្ញាស្មារតីត្រួតត្រាលើចិត្តរបស់ខ្លួនបាន បុគ្គលនោះចាត់ជាអ្នកជាបានទទួលឯករាជ្យពុំស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់កិលេសតណ្ហាទៀតឡើយ ។

ប្រភេទនៃសេរីភាពទាំងពីរនេះ មានលក្ខណៈខុសគ្នាខ្លះ គឺសេរីភាពផ្លូវលោក និយាយពីការរំដោះខ្លួនចេញពីការជិះជាន់ ការគៀបសង្កត់ ការបំបិទសេរីភាពរបស់ជនដទៃ របស់ប្រទេសដទៃ ជាពិសេសរបស់រដ្ឋាភិបាលខ្លួន ។ ការចំរើនលូតលាស់គ្រប់យ៉ាង មានការចំរើនលូតលាស់ខាងវិទ្យាសាស្ត្រជាដើម ដោយសារមនុស្សមានសេរីភាពបំពេញកិច្ចការដោយគ្មានអ្វីមករារាំង ។ ប៉ុន្តែសេរីភាពរបស់ផ្លូវលោក ពុំបាននិយាយអំពីការរំដោះខ្លួនចេញបីកិលេសតណ្ហាឡើយ ។ ចំណែកសេរីភាពខាងផ្លូវធម៌បាននិយាយទាំងពីរ គឺត្រូវរំដោះខ្លួនចេញ ពីការបំបិទសេរីភាពផង ចេញពីកិលេសតណ្ហា ដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនផង ដោយវិធីអប់រំចិត្តក្នុងផ្លូវសមថៈនិងវិបស្សនា តួយ៉ាងដូចជាព្រះពុទ្ធ ដោយសារព្រះអង្គមានសិទ្ធិសេរីភាពក្នុងការស្វែងរកព្រះធម៌ទើបព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ។៚